ភ្នំពេញ,ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០០៣

# សេចក្តីប្រកាសព័ត៌មានរួមរបស់ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការសុខភាពពិភពលោក

## ព្រះរាជាណាចក្រកម្ពុជាពុំទាន់ទទួលការរាតត្បាត ពីជំងឺផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរទេ

ថ្មី ៗនេះមានសារពត៌មាន និងពាក្យចចាមអារាម បានផ្សាយ និងឃោសនាថា មានវិធីបង្ការការឆ្លងជំងឺផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរដែលហៅ (SARS)ដ៏មានប្រសិទ្ធិភាព និងប្រភពពត៌មានក្រៅស្រុកខ្លះទៀតផ្សាយថា មានករណីជំងឺ (SARS) មានប្រភពមកពីព្រះរាជាណាចក្រកម្ពុជា ។

ក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោកប្រចាំនៅកម្ពុជា សូមធ្វើការប្រកាសពត៌មនជាផ្លូវអំពីបញ្ហាខាងលើនេះដូចតទៅ:

រហូតមកដល់ថ្ងៃទី ៨ ខែឧសភា ឆ្នាំ២០០៣ នៅព្រះរាជាណាចក្រកម្ពុជាពុំទាន់មានករណីជំងឺ (SARS) នេះនៅឡើយទេ, យើងបានធ្វើការអង្កេតស្រាវជ្រាវករណីសង្ស័យចំនួន ១២ករណី តែអ្នកជំងឺទាំងនេះពុំបានចូលក្នុងលក្ខខ័ណ្ឌនិយមន័យករណីជំងឺ (SARS) របស់អង្គការសុខភាពពិភពលោកឡើយ ព្រោះពួកគេទាំងនោះមានជំងឺដ៏ទៃមិនមែនជាជំងឺ (SARS) ទេ ។ រហូតមកដល់នេះនៅពុំទាន់មានមធ្យោបាយដ៏មានប្រសិទ្ធិភាព ដើម្បីបង្ការជំងឺ (SARS) នៅឡើយទេ ។ ព្រោះថាថ្មីៗនេះមាន ការផ្សព្វផ្សាយស្តីពីការមានវ៉ាក់សាំងចាក់បង្ការជំងឺ (SARS) ដែលពុំបានពឹងផ្អែកទៅលើមូលដ្ឋានវិទ្យាសាស្រ្ត ព្រមជាមួយគ្នា នោះដែរក៏មានការឃោសនាថាញាំសណ្តែកបាយអាចបង្ការជំងឺ (SARS) ក៏ពុំបានពឹងផ្អែកលើមូលដ្ឋានវិទ្យាសាស្រ្តដែរ យើងខ្ញុំសូមជំរាបជូនសាធារណៈជនឱ្យបានជ្រាបថា ប្រជាជនយើងគួរប្រុងប្រយ័ត្នរាល់ការឃោសនាស្តីពីការដែលមាន ឱសថសំរាប់ បង្ការ ឬព្យាបាលជំងឺ (SARS) ព្រោះវាជាការឃោសនាដើម្បីចំណេញរបស់ឈ្មួញប៉ុណ្ណោះ ។

ទោះបីជារហូតដល់ពេលនេះគ្មានករណីជំងឺ (SARS) នៅព្រះរាជាណាចក្រកម្ពុជាក៏ដោយ ការប៉ះពាល់សេដ្ឋកិច្ចត្រូវបានប៉ះពាល់តាមរយៈការធ្លាក់ចុះនៃអ្នកទេសចរណ៏មកព្រះរាជាណាចក្រកម្ពុជា ។ បើប្រទេសកម្ពុជាក្លាយជាប្រទេសមាន ឧស្សាហកម្មទេសចរណ៏នឹងថយចុះបន្ថែមទៀត ដែលធ្វើឱ្យការប៉ះពាល់សេដ្ឋកិច្ចកាន់តែគ្រោះថ្នាក់ថែមទៀត ។ ដោយហេតុនេះហើយ យើងត្រូវការជាចាំបាច់អោយស្ថាប័នពាក់ព័ន្ធនៅក្នុងរដ្ឋាភិបាល និងសាធារណៈជន ចូលរួមសហការណ៏គ្នាបង្ការការចូល និងរីករាលដាល ជំងឺ (SARS) នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ទាំងនេះមានន័យថា ត្រូវមានការពង្រឹងការសហការណ៏គ្នានៅព្រលានយន្តអន្តរជាតិ ។ កិច្ចការនេះ តំរូវអោយមានកិច្ចសហប្រតិបត្តិការយ៉ាងពេញទំហឹងនូវរាល់ស្ថាប័ណពាក់ព័ន្ធ ក្នុងគោលបំណងពង្រឹងនូវការត្រួតពិនិត្យនៅព្រលានយន្តហោះ។ វាក៏ទាមទារផងដែរនូវការយកចិត្តទុកដាក់ជានិច្ចកាលរបស់មន្ត្រីសុខាភិបាលគ្រប់ប្រភេទ ក្នុងការរកអោយឃើញ និងរាយការណ៏ភ្លាមៗនូវករណីសង្ស័យ។ សាធារណៈជនត្រូវចូលរួមរាយការណ៏ផងដែរពីករណីសង្ស័យ។

រាល់អ្នកណាដែលមានរោគសញ្ញា ក្តៅខ្លួន (លើសពី ៣៨ អង្សាសេ) និង ក្អក ឬ ពិបាកដកដង្ហើម ដែលគិតថាមានទំនាក់ទំនងស្និទ្ធិនឹងអ្នកដែលអញ្ជើញមកពីប្រទេសដែលមានជំងឺ (SARS) ត្រូវរាយការណ៏ជាបន្ទាន់ មកទីកន្លែងទទួលខុសត្រូវជំងឺនោះ។ មកទល់ពេលនេះ ប្រទេសដែលមានកើតមានជំងឺ (SARS) មានជាអាទ៏ ចិន (ទីក្រុងប៉េកាំង ខេត្តក្វាងទុង ក្រុងហុងកុង អ៊ីណើ ម៉ុងហ្កោលី ខេត្តសាងស៊ី ទៀនជីន និងកោះតៃវ៉ាន់) សឹង្ហបុរី ហ្វីលីពីន ម៉ុហ្កោលី និង ប្រទេសកាណាដា។